# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាល់-យ៉ាវ៉ាដ្ដ់ صلوات الله عليه والسلام



សៃយីដ្ធ ម៉ាស្វ់ឌ្វី អាយ៉ាទុលឡ៍ហ៊ី

ស្ហាគីប បេនបេឌីរ៉ា

الجواد

# បញ្ជីមាតិកា


កំណើត ........................................ 4

ឪពុកមា(ឬឪពុកធំ)ភ័ក្តី ........................................ 6

ពន្លឺសីលធម៌របស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 6

ចិត្តបុណ្យស្នូវង្សត្រកូល ........................................ 8

អាពាហ៍ពិពាហ៍របស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 11

ការប្រឈមមុខគ្នាក្នុងវិស័យវិទ្យាសាស្ត្រ ........................................ 16

ត្រឡប់មកកាន់ម៉ាឌីណាស៊ុំវិញ ........................................ 18

បង្គាប់ឲ្យប្រព្រឹត្តល្អ ........................................ 19

អវសានរបស់អាល់-ម៉ាក់មូន ........................................ 22

ទុក្ករៈកម្មរបស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 24

រាជបុត្ររាជធិតារបស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 25

សម្រង់ព្រះវចនៈត្រចះត្រចង់ ........................................ 27

អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 29

# កំណើត

អ៊ីម៉ាំអាស់លុល-បៃត៏ ទី ៩ អ៊ីម៉ាំ មូហាំម៉ាដ្ទ អាល់-យ៉ាវ៉ាដ្ទ صلوات الله عليه والسلام បានប្រសូត ថ្ងៃទី ១០ ខែរ៉យ៉ាប់ ឆ្នាំ ១៩៥ សករាជហ៊ីជ្ជរ៉ោះត្ទ៏ នៅឯម៉ាឌីណាស្ទ ។

ព្រះមាតាព្រះអង្គមានព្រះនាមថា ខ្ទយ់ស៊ូរ៉ន (خيزران) ជារាជវង្សរបស់ម៉ារីយ៉ាស្ទ ព្រះមហេសីរបស់ព្រះសាស្តា صلى الله عليه وآله وسلم ។

ព្រះអង្គបានរស់នៅជាមួយព្រះបិតាព្រះអង្គ អ៊ីម៉ាំអាររីដ្ទ៏ صلوات الله عليه والسلام បាន ៧ ឆ្នាំ ។ កាលអ៊ីម៉ាំអាររីដ្ទ៏ صلوات الله عليه والسلام ត្រូវគេធ្វើគុត ព្រះអង្គបានទទួលភារៈដឹកនាំសាសនានិងច្បាប់ដ៏ធ្ងន់របស់សហគមន៍មុស្លីម ក្នុងព្រះជន្មក្មេងខ្ចី បញ្ជាក់ឲ្យឃើញថាបេសកកម្មព្រះអង្គជាបេសកកម្មដែលមកពីព្រះ ។ មានតែអ្នកភ័ក្តីចំពោះអាស់លុល-បៃត៏ عليهم السلام ទេដែលអាចយល់រឿងនេះ ។

ព្រោះតែអ៊ីម៉ាំ មូហាំម៉ាដ្ទ ប៊ិន អាលី صلوات الله عليه والسلام មានគុណសម្បត្តិវិសាមញ្ញ គេបានដាក់ព្រះនាមច្រើនឲ្យព្រះអង្គ ។ ព្រះនាមពីរដែលល្បីជាងគេគឺៈ អាត់-តាគ្គី (التقي) មានន័យថា បុគ្គលអ្នកមានសទ្ធាស៊ប់ចិត្ត និង អាល់-យ៉ាវ៉ាដ្ទ (الجواد) មានន័យថា បុគ្គលអ្នកមានចិត្តបុណ្យជាទីបំផុត ។

អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ទ صلوات الله عليه والسلام មានព្រះជន្ម ៦ វស្សាកាលអាល់-ម៉ាក់មូនបាន



# អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

-ព្រះនាម ៖ មូហាំម៉ាដ្ទ ។

-ព្រះនាមចំតើត ៖ អាល់យ៉ាវ៉ាដ្ទ, អាត់-តាគ្គី ។

-ព្រះគារវៈនាម ៖ អាប៊ូ យ៉ាក់ហ្វារ ។

-ព្រះនាមព្រះបិតា ៖ អ៊ីម៉ាំ អាររីដ្ទ៏ صلوات الله عليه والسلام ។

-ថ្ងៃប្រសូត ៖ ថ្ងៃទី ១០ ខែរ៉យ៉ាប់ ឆ្នាំ ១៩៥ សករាជហ៊ីជ្ជរ៉ោះត្ទ៏ នៅឯម៉ាឌីណាស្ទ ។

-ថ្ងៃចូលទិវង្គត(ទទួលទុក្ករកម្ម) ៖ ថ្ងៃទី ៣០ ខែស៊ុលក្ទ៏អ៊ីដ្ទាស្ទ ឆ្នាំ ២២០ សករាជ ហ៊ីជ្ជរ៉ោះត្ទ៏ ។

-កន្លែងបញ្ចុះព្រះរាជសព ៖ អាល់-កាស្ទិមីយ៉ាស្ទ (ប្រទេសអ៊ីរ៉ាក្ទ) ។

ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ

30/07/2016





កោះហៅអ៊ីមុាំអារីដ្ហ صلوات الله عليه والسلام ទៅកាន់ម៉ារូ ។ ព្រះអង្គបានចូលរួមក្នុងពិធីបំពេញតាវ៉ាហ្វជុំវិញកាក់បាស្ហ់របស់ព្រះបិតាព្រះអង្គ ។ ព្រះអង្គយល់ច្បាស់ថានេះគឺការលារបស់ព្រះអង្គ ហើយព្រះអង្គនឹងមិនវិលត្រឡប់មកកាន់លំនៅដ្ឋានព្រះអង្គវិញឡើយ ។

មុននឹងចាកចេញទៅកាន់ស្រុកម៉ារូ អ៊ីមុាំអារីដ្ហ صلوات الله عليه والسلام បានប្រាប់អ្នកជំនិតនិងសាវកទាំងអស់របស់ព្រះអង្គថា ព្រះអង្គតែងតាំង មូហាំម៉ាដ់ ព្រះរាជបុត្ររបស់ព្រះអង្គជាអ្នកស្នងព្រះអង្គ ហើយសូមឲ្យពួកគេតាមនិងស្តាប់ឱវាទព្រះអង្គ ។

ការតែងតាំង អ៊ីមុាំអាល់–យ៉ាវ៉ាដ់ صلوات الله عليه والسلام បានប្រព្រឹត្តទៅតាំងពីបីឆ្នាំមុនម៉្លេះបើយោលតាមសម្តីរបស់លោកស្វហ្វវ៉ាន ប៊ិន យ៉ាស្ហ៊យ៉ា ព្រោះកាលនោះលោកបានសួរអ៊ីមុាំអារីដ្ហ صلوات الله عليه والسلام ថាអ្នកណាជាអ្នកស្នងព្រះអង្គ? ព្រះអង្គបានតែងតាំងមូហាំម៉ាដ់ បុត្រព្រះអង្គ ។ ភ្ញាក់ផ្អើល ស្វហ្វវ៉ានក៏បានសួរព្រះអង្គថា៖

– ព្រះអង្គទើបតែមានព្រះជន្មបីវស្សាទេ?

– មានខុសអ្វី ។ អ៊ីសា عليه السلام ជាព្រះទូតរបស់អល់ឡោះហ៏ عز وجل តាំងពីមុន

ព្រះអង្គមានព្រះជន្មាយុបីខួបម្ល៉េះ ។

## ឪពុកមា(ឬឪពុកធំ)ភ័ក្តី

អ៊ាលី ប៊ិន យ៉ាក់ហ្វារ ឪពុកមា (ឪពុកធំ) របស់អ៊ីម៉ាំមូហាំម៉ាដ្ឋ់ អាល់-យ៉ាវ៉ាដ្ឋ់ صلوات الله عليه والسلام គោរពគ្នួយរបស់ខ្លួនណាស់ ទោះជាអ្នកទាំងពីរមានអាយុខុសគ្នាច្រើនក៏ដោយ ។ អ៊ាលី ប៊ិន យ៉ាក់ហ្វារមិនដែលហ៊ានអង្គុយមុនអ៊ីម៉ាំមូហាំម៉ាដ្ឋ់ អាល់-យ៉ាវ៉ាដ្ឋ់ صلوات الله عليه والسلام ឡើយ ។ ពេលសាច់ញាតិលោកបន្ទោសលោកអំពីអាកប្បកិរិយានេះដែលពួកអារ៉ាប់មិនអាចយល់បាននោះ លោកបានតបវិញថា៖ «អល់ឡោះហ៊្ជ عز وجل បានតែងតាំងព្រះអង្គជាអ៊ីម៉ាំ ។ យើងត្រូវតែស្តាប់បង្គាប់ព្រះអង្គ ។»

## ពន្លឺសីលធម៌របស់អ៊ីមុាំ صلوات الله عليه والسلام

ទោះជាព្រះអង្គមានព្រះជន្មក្មេងខ្ចីក៏ដោយ អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ឋ صلوات الله عليه والسلام មានបុគ្គលលក្ខណៈរឹងមាំណាស់ បណ្តាលឲ្យគូសន្ទនារបស់ព្រះអង្គគោរពនិងស្ញប់ស្ញែងព្រះអង្គជាទីបំផុត ។

ថ្ងៃមួយ កាលព្រះអង្គជាកុមារភាពនៅឡើយ អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ឋ់ صلوات الله عليه والسلام



## សម្រង់ព្រះវចនៈត្រចះត្រចង់

– សេចក្តីថ្លៃថ្នូររបស់អ្នកមានសទ្ធាស្ថិតនៅលើអព្យាក្រឹតភាព ។

– អ្នកមានសទ្ធាត្រូវមានគុណសម្បត្តិបីគឺ៖

  – គោលដៅល្អទៅរកអល់ឡោះហ៊្ជ عز وجل ។

  – ការដាស់តឿនខ្លួនឯង ។

  – ព្រមទទួលយកយោបល់អ្នកដទៃ ។

– ថ្ងៃកាត់ក្តីពិបាកសម្រាប់បុគ្គលទុច្ចរិត ជាងថ្ងៃអយុត្តិធម៌សម្រាប់បុគ្គលដែលធ្វើអំពើអយុត្តិធម៌នោះទៀត ។

– ដរាបណាសាសនាមិនមានឥទ្ធិពលលើអារម្មណ៍ របស់អ្នកមានសទ្ធាទេ ដរាបនោះអ្នកមានសទ្ធានឹងមិនជឿពិតប្រាកដទេ ។

– មនុស្សច្រើនតែស្លាប់ដោយសារបាបកម្មរបស់ខ្លួន ជាជាងស្លាប់ដោយសារកាលបរិច្ឆេទដែលបានកំណត់ហើយនោះ ។ ជីវិតរបស់មនុស្សត្រូវបន្លាយដោយសារអំពើល្អជាជាងដោយសារអាយុដែលបានកំណត់ហើយនោះ ។

ដោយសិរីសួស្តី ហើយគេដាក់ឈ្មោះចំកើតឲ្យលោកថា អាប៊ូ អាស៊ុម៉ាដ់ ។

- ហ៊ូសៃន៍ (ត្រូវគេដាក់ឈ្មោះចំកើតឲ្យលោកដែរថា អាប៊ូ អាស៊ុម៉ាដ់) ។
- អ៊ុម៉ាន (ត្រូវគេដាក់ឈ្មោះចំកើតឲ្យលោកថា អាប៊ូ មូសា) ។

- បុត្រី ៖

- ហ្វាទីម៉ាស់ ។
- ខ៊ឌីយ៉ាស់ ។
- អ៊ុម អាល់-កាល់ស៊ូម ។
- ហាគីម៉ាស់ ។

ស្ហៃខ៍ អាប់បាស់ អាល់-គុម្មីបានថ្លែងឈ្មោះ ស៊ៃណាប់, អ៊ុម មូហាំម៉ាដ និង ម៉ៃមូណាស់នៅក្នុងសាត្រា មុនតាហា អាល់-អាម៉ាល់ (منتهى الآمال) របស់លោក ។





បានលេងជាមួយកុមារនានាក្នុងផ្លាមួយ ចំពេលដែលស្ដេចខ៏លិហ្វ អាល់-ម៉ាក់មូនមកដល់ជាមួយបរិវារ ។ ក្មេងទាំងឡាយបានរត់គេចអស់ សល់តែអ៊ីម៉ាំ-អាល់យ៉ាវ៉ាដ់ صلوات الله عليه والسلام ដែលនៅមួយកន្លែង ។ អាល់-ម៉ាក់មូន សម្លឹងព្រះអង្គដោយចាប់អារម្មណ៍ ហើយបានថា៖ «ហេតុអ្វីឯងមិនរត់ដូច ក្មេងៗឯទៀត?» អ៊ីម៉ាំ-អាល់យ៉ាវ៉ាដ់ صلوات الله عليه والسلام បានតបថា៖ «ផ្លូវមិនចង្អៀតទេ ខ្ញុំមិនចាំបាច់ចៀសផ្លូវឲ្យលោកទេ ។ ម្យ៉ាងទៀតខ្ញុំមិនបានធ្វើអ្វីខុសដែល បណ្ដាលឲ្យខ្លាចទណ្ឌកម្មនោះទេ ។ ហើយខ្ញុំគោរពសីលធម៌លោកគឺ៖ លោក មិនធ្វើទណ្ឌកម្មអ្នកស្លូតត្រង់ទេ ។ ដូច្នេះខ្ញុំនៅមួយកន្លែង ។» អាល់-ម៉ាក់មូន ចាប់អារម្មណ៍សម្ដីសមហេតុផលរបស់ក្មេងប្រុសរូបនេះ ដែលខ្លួនមិនទាន់ ស្គាល់ បានសួរថា៖ «ឯងឈ្មោះអ្វី?» អ៊ីម៉ាំបានតបថា៖ «មូហាំម៉ាដ់ ប៊ិន អ៊ុាលី អារីដ្ឋ៍ ។» អាល់-ម៉ាក់មូនក៏បានយល់ភ្លាមនូវអាថ៌កំបាំងថ្កុំថ្កើងរបស់ក្មេង ប្រុសរូបនេះ ហើយបានប្រាប់ឲ្យបរិវារខ្លួនបួងសួងឲ្យអ៊ីម៉ាំអារីដ្ឋ៍ صلوات الله عليه والسلام រួច ហើយក៏បានបន្តដំណើរ ។

## ចិត្តបុណ្យស្នូវង្សត្រកូល

ចិត្តបុណ្យជាចំណុចសំខាន់សម្រាប់សំណាក់មុស្លីម ។ អាស់លុល-បៃត៍



នាក់ចូលចិត្តសំដៅទៅទស្សនារៀងរាល់ឆ្នាំ ។

## រាជបុត្ររាជធិតារបស់អ៊ីម៉ាំ صلوات الله عليه والسلام

គេដឹងថាអ៊ីម៉ាំអាល់-យ៉ាវ៉ាដ់ صلوات الله عليه والسلام មានមហេសីតែពីរនាក់ទេគឺ៖

-អ៊ុម អាល់-ហ្វាឌ្ហីល បុត្រីរបស់អាល់-ម៉ាក់មូន ។ ព្រះអង្គមិនមានបុត្រ ជាមួយមហេសីរូបនេះទេ ។

-សាម៉ាណាស្ហ៍ អាល់-ម៉ាក់រីប៊ីយ៉ាស្ហ៍ (سمانة المغربية) ជាមាតារបស់អ៊ីម៉ាំទី ១០ អ៊ីម៉ាំអាល់-ហាឌី صلوات الله عليه والسلام ។ គេបានឲ្យដឹងទៀតថាមហេសីរបស់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ់មាននាមថា អ៊ុម អាល់-ហាឌី (អ៊ុម វ៉ាឡាដ់ (أم ولد) មានន័យថា ម្ដាយរបស់កូនម្នាក់) ជាមាតារបស់អ៊ីម៉ាំទី ១០ អ៊ីម៉ាំអាល់-ហាឌី صلوات الله عليه والسلام ថាអ៊ីម៉ាំ អាល់-យ៉ាវ៉ាដ់និងអ៊ុម អាល់-ហាឌីមានបុត្រាពីរនាក់ បុត្រីពីរនាក់ ឬ បុត្រា បួននាក់ បុត្រីបួននាក់គឺ៖

- បុត្រា៖

  -អាប៊ូ អាល់-ហាសាន់ (អ៊ុាលីអាល់-ហាឌី ឬ អាន់-គ្គី ឬ អាត់-តាគ្គី) ដែលជាអ៊ីម៉ាំបន្ទាប់ពីព្រះអង្គ ។

  -មូសា អាល់-មុបរ៉ាក្គ៏អ៊ុ (ក្លាយមកពី ប៊ូរក្គ៏អ៊ុ) មានកូនចៅប្រែកប

## ទុក្ករៈកម្មរបស់អ៊ីម៉ាំ صلوات الله عليه والسلام

*អាល់-មុអ៏តាស៊ីម ប្រញាប់ប្រញាល់កោះហៅអ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ង់ទៅកាន់បាក់ដាដ្ង់ដើម្បីរៀបចំផែនការណ៍ធ្វើឃាតកម្មព្រះអង្គ ។ យ៉ាក់ហ្វារ កូនរបស់អាល់-ម៉ាក់មូនបានដាក់បញ្ជាឲ្យប្អូនស្រីរបស់ខ្លួន ពោលគឺ មហេសីរបស់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ង់ ដាក់ថ្នាំបំពុលព្រះអង្គដោយប្រើវិធីតែមួយដូចកាលធ្វើឃាតកម្មព្រះបិតាព្រះអង្គដែរ ។*

*អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ង់បានត្រឡប់ទៅឯព្រះម្ចាស់ عزّ وجلّ ព្រះអង្គវិញ ក្នុងព្រះជន្ម ២៥ វស្សាបន្ទាប់ពីបានសោយទំពាំងបាយជូរដែលមហេសីព្រះអង្គបានដាក់ថ្នាំបំពុល ។*

*សូមសិរីសួស្តីកើតមានដល់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ង់ និងអាស់លុល-បៃត៍ عليهم السلام ទាំងអស់ ។*

*អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ង់បានទទួលទុក្ករៈកម្មថ្ងៃទី ៣០ ខែស៊ុលក៏អ៊ីដាស់ ឆ្នាំ ២២០ សករាជ ហ៊ិជ្ជរ៉ោះត៍ ។ ព្រះរាជសពព្រះអង្គត្រូវបញ្ចុះនៅឯសុសាន គូរ៉យស្ង៍ ស្រុកបាក់ដាដ្ង់ ដែលសព្វថ្ងៃគេហៅថា អាល់-កាស៊្ញីមីយ៉ាស់ ក្នុងផ្នូរព្រះអយ្យកោព្រះអង្គ អ៊ីម៉ាំមូសា អាល់-កាស៊្ញីម صلوات الله عليه والسلام ។*

*រហូតមកដល់សព្វថ្ងៃ ព្រះចេតិយអ៊ីម៉ាំជាស្ថានទីដែលមូស្លីមរាប់លាន*





عليهم السلام តែងតែជាគំរូល្អបំផុតរបស់សីលធម៌នេះ ដែលឆ្លុះបញ្ចាំងឲ្យឃើញវិញ្ញាណឧត្តុង្គឧត្តម ចិត្តទូលំទូលាយនិងការមិនអើពើជីវិតលោកនេះ ។

អ៊ីមុាំអារើដ្ហ៍ صلوات الله عليه والسلام ត្រូវបង្ខំឲ្យទទួលតំណែងជា “អ្នកស្នងអំណាចពួកអ្កាប់បាស់” ចំណែកឯព្រះរាជបុត្រព្រះអង្គក៏មានបរិវារអមតាមដែរ ។

អ៊ីមុាំអារើដ្ហ៍ صلوات الله عليه والسلام រំលឹកព្រះរាជបុត្រព្រះអង្គ ថាកុំបណ្ដោយឲ្យភាពឧត្តុង្គឧត្តមនិងចិត្តទូលំទូលាយរបស់ព្រះអង្គអាប់ឱនឡើយ ដោយសារតែសេចក្ដីលោភលន់និងសេចក្ដីកំណាញ់របស់ពួកបរិវាររបស់ព្រះអង្គ ដោយសរសេរសំបុត្រមួយច្បាប់ផ្ដាំផ្ញើព្រះអង្គថាៈ «អាប៊ូ យ៉ាក្ហ៍ហ្វារអើយ បិតាបានឮថាពួកបម្រើឲ្យបុត្រឆ្លងកាត់តាមទ្វារតូច ពេលបុត្រចេញទៅខាងក្រៅ ។ នេះមកពីពួកគេកំណាញ់ ។ ពួកគេធ្វើដូច្នេះព្រោះតែមិនចង់ឲ្យអ្នកណាម្នាក់បានទទួលនូវសប្បុរសធម៌ពីបុត្រឡើយ ។ ដូច្នេះ អាស្រ័យលើសិទ្ធិរបស់បិតាដែលមានលើបុត្រនោះ បិតាសូមឲ្យបុត្រចេញចូលតាមតែទ្វារធំ ។ ហើយពេលបុត្រចេញចូល ចូរបុត្រដាក់មាសនិងប្រាក់ជាប់ខ្លួនជានិច្ច ។ កាលណាគេសូមឲ្យបុត្រជួយ ចូរបុត្រជួយគេ ។ បើឪពុកមា(ឬឪពុកធំ)ណាម្នាក់របស់បុត្រសូមឲ្យបុត្រជួយប្រោសប្រណី ចូរបុត្រកុំឲ្យឪពុកមា(ឬឪពុកធំ)នោះតិចជាងហាសិប





លោកមិនឃើញមានអ្នកណាមួយសក្តិសមទេ សម្រាប់លោក ។ សូមឲ្យអល់ឡោះហ៑ عزّ وجلប្រោសមេត្តាលោក ចូរលោកកុំគិតពីចំណុចនេះឡើយ ។ ព្រះសាស្តា صلى الله عليه وآله وسلمមានព្រះវចនៈថា៖ “បើមានអ្នកណាម្នាក់ដែលអស់លោកព្រមទទួលស្គាល់ជំនឿនិងអាកប្បកិរិយាមកសូមរៀបអាពាហ៍ពិពាហ៍ ចូរអស់លោករៀបអាពាហ៍ពិពាហ៍ឲ្យគេទៅ ។ បើអស់លោកមិនធ្វើដូច្នេះទេ នឹងមានការប្រយុទ្ធនៅលើផែនដីនិងសេចក្តីវិនាសជាទូទៅ ។”»

## អវសានរបស់អាល់-ម៉ាក់មូន

ប្រជារាស្ត្រប្រទេសអេស៊ីបត៍បានបះបោរ ។ អាល់-ម៉ាក់មូនបានដឹកនាំទ័ពធំមួយដោយខ្លួនឯង ហើយបានបង្ក្រាបការបះបោរនេះ ។ បន្ទាប់មកអាល់-ម៉ាក់មូនបានបែរទៅបង្ក្រាបពួកប៊ីសង់តាំង (ពួករ៉ូម) ។ ពេលត្រឡប់មកកាន់អ៊ីរ៉ាក់វិញ អាល់-ម៉ាក់មូនធ្លាក់ខ្លួនឈឺនៅឯស្រុក អៀរ៉ាក់ក្រោះត្ត៍ (الرقة) ហើយបានបញ្ជាឲ្យបោះជុំរុំក្នុងតំបន់នេះ ។ មិនយូរប៉ុន្មានអាល់-ម៉ាក់មូនក៏បានស្លាប់ ចោលអំណាចឲ្យទៅប្អូនប្រុសដែលតឹងរ៉ឹងនិងសាហាវលើសនោះ ឈ្មោះ អាល់-មុអ៍តាស៊ឹម (المعتصم) ។



ឌីណារឡើយ ។ បើបុត្រចង់ឲ្យច្រើនជាងនោះ ស្រេចតែលើបុត្រ ។ បើម្តាយមីង(ឬម្តាយធំ)របស់បុត្រសូមឲ្យបុត្រជួយប្រោសប្រណី ចូរបុត្រកុំឲ្យម្តាយមីង(ឬម្តាយធំ)នោះតិចជាងថ្លៃប្រាំឌីណារឡើយ ។ បើបុត្រចង់ឲ្យច្រើនជាងនោះ ស្រេចតែលើបុត្រ ។ បិតាចង់ឲ្យអល់ឡោះហ៑ عزّ وجلលើកតម្កើងបុត្រ ។ ដូច្នេះចូរបុត្របរិច្ចាគ ហើយចូរបុត្រកុំខ្លាចថាអល់ឡោះហ៑ عزّ وجلនឹងដាក់ភាពតឹងរ៉ឹងមកលើបុត្រឡើយ ។

## អាពាហ៍ពិពាហ៍របស់អ៊ីមុាំ صلوات الله عليه والسلام

បន្ទាប់ពីអ៊ីមុាំអារីដ្ឋ صلوات الله عليه والسلامបានទទួលទុក្ករកម្ម មូស្លីមទាំងអស់ដែលស្មោះត្រង់និងស្គាល់អំណាចពិតប្រាកដរបស់ពួកអ៊ុំប់បាស់នោះ បានចោទប្រកាន់ស្តេចខ៏លិហ្វអាល់-ម៉ាក់មូនថាជាឃាតកររបស់អ៊ីមុាំអារីដ្ឋ صلوات الله عليه والسلام ។ អាល់-ម៉ាក់មូនមិនឥតដឹងថាប្រជារាស្ត្រគិតអ្វីនោះទេ ។ ដូច្នេះហើយបានជាស្តេចខ៏លិហ្វរូបនេះបានសម្រេចចិត្តប្រតិបត្តិការមួយ ដែលធ្វើឲ្យខ្លួនបានសម្រេចគោលដៅពីរគឺ៖ ទីមួយគឺធ្វើឲ្យគេឈប់សង្ស័យមកលើខ្លួន ។ ទីពីរគឺគ្រប់គ្រងអ្នកស្នងអ៊ីមុាំអារីដ្ឋ صلوات الله عليه والسلام អ៊ីមុាំថ្មីដែលជាទឡ្ហការីរបស់អល់ឡោះហ៑ عزّ وجلនៅលើផែនដី មូហាំម៉ាដ់ ប៊ិន អ៊ាលី ដែលមានព្រះជន្មត្រឹមតែ ៧ វស្សា







អាស្វុលុល-បៃត៍ عليهم السلام ក៏ដោយ ក៏នៅតែខិតខំអនុវត្តន៍តាមគោលនយោបាយអយុត្តិធម៌របស់ស្តេចខ៏លិហ្វ ដោយតម្រូវឲ្យប្រជារស្ត្រស្រុកនេះ ដែលនៅក្រោមការត្រួតត្រារបស់ខ្លួន ក្នុងតំបន់នីស្វាប៊ូរ បង់ពន្ធយ៉ាងធ្ងន់ ។ ព្រះអង្គបានផ្ញើសំបុត្រទៅអភិបាលខេត្តថា៖ «ក្នុងព្រះនាមអល់ឡោះហ៊ូ عز وجل ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ អ្នកនាំសាររបស់ខ្ញុំបានប្រាប់ខ្ញុំថាលោកជាអ្នកសទ្ធាជ្រះថ្លាម្នាក់ ។ ដូច្នេះចូរលោកជ្រាបថា អ្វីដែលលោកទទួលបានពីទង្វើរបស់លោកនោះគឺអំពើល្អ ។ ដូច្នេះចូរលោកប្រព្រឹត្តល្អចំពោះបងប្អូនលោក ។» លុះអភិបាលខេត្តនីស្វាប៊ូរបានទទួលសំបុត្រនេះ លោកបានយកសំបុត្រនេះមកបើប យកមកដាក់លើភ្នែក ហើយសួរអ្នកនាំសារនេះថា៖ «លោកមានការអ្វី?» បុរសនោះបានតបថា៖ «ខ្ញុំត្រូវបង់ពន្ធ ។» អភិបាលខេត្តបានតបវិញថា៖ «កុំបង់ពន្ធ ។ ដរាបណាខ្ញុំនៅទីនេះ ដរាបនោះលោកមិនបង់ពន្ធឡើយ ។»

បុរសម្នាក់បានសរសេរសំបុត្រទៅសួរអ៊ីមុាំអាល់-យ៉ាវ៉ាដ់ صلوات الله عليه والسلام អំពីការរៀបអាពាហ៍ពិពាហ៍របស់កូនស្រីគាត់ ។ អ៊ីមុាំបានសរសេរមកគាត់ថា៖ «ខ្ញុំដឹងរឿងដែលលោកបានរៀបរាប់ប្រាប់ខ្ញុំ អំពីកូនស្រីរបស់លោកហើយ



ប៉ុណ្ណោះ ។

ដូច្នេះស្តេចខ៏លិហ្វបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ មូហាំម៉ាដ់ អាល់-យ៉ាវ៉ាដ់ជាមួយបុត្រីរបស់ខ្លួនឈ្មោះ អ៊ុម អាល់-ហ្វាឌ្វីល (أم الفضل)។

ព្រោះតែខ្លាចអំណាចរបូតពីដៃខ្លួន អស់អង្គម្ចាស់ត្រកូលអាប់បាស់បានមកជួបអាល់-ម៉ាក់មូន សូមឲ្យបកក្រោយវិញ ។ អាល់-ម៉ាក់មូនបានពន្យល់ប្រាប់ពួកគេនូវគោលបំណងពិតរបស់ខ្លួន តែពួកគេមួយចំនួននៅតែមិនយល់ព្រម ដោយអះអាងថាមូហាំម៉ាដ់ អាល់-យ៉ាវ៉ាដ់នៅក្មេងពេក មិនទាន់ស្គាល់ការទទួលខុសត្រូវភារៈគ្រួសារនៅឡើយទេ ហើយមិនស្គាល់គោលការណ៍សាសនានិងច្បាប់ទេ ។ ពេលបានឮសម្តីនេះ អាល់-ម៉ាក់មូនឆ្ងៀតយកឱកាសដើម្បីចុកមាត់ពួកគេជាអចិន្ត្រៃយ៍តែម្តង ព្រោះខ្លួនស្គាល់ច្បាស់ថា មូហាំម៉ាដ់ អាល់-យ៉ាវ៉ាដ់ ជាអ្នកណា មានវ័យចំណាស់ប៉ុណ្ណា ហើយមានចំណេះប៉ុណ្ណា ។ អាល់-ម៉ាក់មូនក៏បានកោះហៅអភិជនអាប់បាស់និងអ្នកប្រាជ្ញទាំងឡាយក្នុងសម័យនោះ និងអ៊ីមុាំអាល់-យ៉ាវ៉ាដ់មកប្រជុំនៅឯរាជវាំង ។ អ៊ីមុាំអាល់-យ៉ាវ៉ាដ់ ត្រូវប្រឈមទល់មុខពួកអភិជននិងពួកអ្នកប្រាជ្ញរបស់រាជវាំង ។ បុគ្គលល្បីជាងគេក្នុងចំណោមជនទាំងនេះគឺ យ៉ាស្ហ៊ុយ៉ា ប៊ិន





មុស្លីមបាននាំគ្នាមកលាព្រះអង្គ ។ ព្រះអង្គបានឈប់ដើម្បីបំពេញស៊ឡាត់ក្នុងម៉ាស់យ៊ីដស្រុកនោះ នៅក្បែរគុម្ពោតឈើព្រៃមានផ្លែ ។ គួរអស្ចារ្យ គុម្ពោតឈើនេះមានផ្លែឆ្ងាញ់ជាពិសេស ហើយច្រើនខុសធម្មតាអស់រយៈពេលច្រើនឆ្នាំ ។ ពួកអ្នកស្រុកគិតថានេះដោយសារតែគុណបុណ្យរបស់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ទ ។

## បង្គាប់ឲ្យប្រព្រឹត្តល្អ

អ៊ីម៉ាំអាស់លុល-បៃត៍ عليهم السلام ទាំងអស់ជាអ្នកបង្គាប់ឲ្យប្រព្រឹត្តល្អ និងជាអ្នកហាមប្រព្រឹត្តអាក្រក់គំរូ ។ នេះជាកាតព្វកិច្ចមួយដែលជាមូលដ្ឋានរបស់សាសនាអ៊ីស្លាមគឺៈ បង្គាប់ឲ្យប្រព្រឹត្តល្អ ហាមប្រព្រឹត្តអាក្រក់ (الأمر بالمَعْرُوف والنَهى عن المُنْكَر) ។ តទៅនេះយើងនឹងលើកឡើងនូវឧទាហរណ៍មួយសម្រាប់ប៉ែកនីមួយនៃពាក្យស្លោកនេះ ។ ឧទាហរណ៍ទាំងនេះជាសាររបស់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ទ ដែលព្រះអង្គផ្ញើទៅឲ្យបុគ្គលដែលជឿជាក់ថាចាំបាច់ត្រូវតែគោរពអ៊ីម៉ាំសម័យកាល ។

កាលព្រះអង្គទៅកាន់តំបន់ហ៊ីយ៉ាស់ដើម្បីទៅបំពេញពិធីហាជ្ជ អ៊ីម៉ាំអាល់-យ៉ាវ៉ាដ្ទដឹងថាអភិបាលខេត្តម្នាក់របស់ពួកអាប់បាស់ ទោះជាស្រឡាញ់

តើសត្វនោះតូចឬធំ ? តើអ្នកប្រមាញ់ស្លាយក្រោយឬទេ ? តើសត្វនោះត្រូវសម្លាប់ពេលយប់ក្នុងសំបុកវាឬពេលថ្ងៃនៅខាងក្រៅសំបុក ? តើជាសំលៀកបំពាក់អ៊ិះហ្ស៊ំមែសម្រាប់បំពេញពិធីអ៊ុមរ៉ោះត៍ឬពិធីហាជ្ជ ?» ប៊ិន អាក់ស្ហ៊ំខ្មាស់គេណាស់ ដោយសារសេចក្ដីរៀបរាប់ទាំងនេះដែលគាត់មិនបានគ្រោងទុកមុន ។ គាត់មានអារម្មណ៍ហាក់ដូចជាត្រូវគេបំពារបំពាន ត្រូវគេបំបាក់មុខ ។ មនុស្សដែលនៅក្នុងសវនាការនេះស្រឡាំងកាំងខ្លាំង ពេលដែលបានអង្គុយស្ដាប់ដូចក្មេងរៀន អ៊ីមុាំអាល់-យ៉ាហ្យ៉ាបរិយាយលំអិតចម្លើយនីមួយៗតាមគ្រប់សំណួររបស់ ប៊ិន អាក់ស្ហ៊ំ ។

ពួកអង្គម្ចាស់និងអភិជនទាំងឡាយមិនដឹងជានិយាយអ្វីឬធ្វើអ្វី ក៏បានចាកចេញពីរាជវាំងដោយដាក់មុខ និងបោះមុខ ។

## ត្រឡប់មកកាន់ម៉ាឌីណាស់វិញ

អ៊ីមុាំអាល់-យ៉ាហ្យ៉ាមានបំណងវិលត្រឡប់មកកាន់ម៉ាឌីណាស់វិញ ។ ព្រះអង្គក៏បានប្រកាស់សេចក្ដីសម្រេចចិត្តទៅបំពេញពិធីហាជ្ជ ។ រៀបចំដំណើរស្រេចបាច់ហើយ អ៊ីមុាំនិងបណ្ដាសាវកព្រះអង្គបានធ្វើដំណើរទៅកាន់តំបន់ហ៊ីជ្ជយ៉ាស់ (الحجاز) កាត់តាមផ្លូវគូហ្វាស់ ។ មកដល់បរិវេណបាក់ដាដ់ ពួក



អាក់ស្ហ៊ំ (يحيى بن أكثم) ដែលជាអ្នកវិទ្យាសាស្ត្រនិងជាអ្នកជំនាញច្បាប់ដែលមានតំណែងជាចៅក្រមលើចៅក្រមទាំងអស់ ។

យើងនឹងបានដឹងនៅពេលខាងមុខនេះថា នៅក្នុងការប្រឈមមុខគ្នានោះ អ៊ីមុាំអាល់-យ៉ាហ្យ៉ាបានទទួលជ័យជំនះ ព្រះអង្គបានឆ្លើយតបគូប្រកួតព្រះអង្គយ៉ាងច្បាស់លាស់ ដោយគ្មានចម្លើយតបព្រះអង្គវិញឡើយ ។

អាល់-ម៉ាក់មូនបានបែរមករកបណ្ដាអ្នកមានវត្តមានក្នុងសវនាការ បានរំលឹកប្រាប់ពួកគេថាក្មេងប្រុសនេះជាអ្នកណា ទុកឲ្យពួកគេនៅទល់មុខនឹងលទ្ធផលដែលបានសម្រេចហើយ រួចហើយបានប្រកាសចាប់ផ្ដើមពិធីអាពាហ៍ពិពាហ៍ ។ អ៊ីមុាំអាល់-យ៉ាហ្យ៉ាបានធ្វើពិធីស្ដីដណ្ដឹងតាមទំនៀមអាពាហ៍ពិពាហ៍ ។ គេបានថ្លែងកិច្ចព្រមព្រៀងនិងកិច្ចសន្យាអាពាហ៍ពិពាហ៍តាមច្បាប់ ហើយបានដាក់ខាន់ស្លាដែលមានតម្លៃស្មើខាន់ស្លារបស់ហ្វាទីម៉ាស់អាស់ស្ហាស់រ៉អ៊ុ سلام الله عليها ដែរ ។ គេក៏បានប្រកាសពិធីបុណ្យអាពាហ៍ពិពាហ៍អាល់-ម៉ាក់មូនប៉ងទទួលបាននូវប្រិយភាពពីសំណាក់មុស្លីម ដែលជំពាក់ចិត្តទៅលើអាស់លុល-បៃត៍ عليهم السلام ជាដរាប ទោះជាពួកគេមិនបានអនុវត្តន៍ឲ្យដូចនឹងចិត្តពួកគេក៏ដោយ ។

## ការប្រឈមមុខគ្នាក្នុងវិស័យវិទ្យាសាស្ត្រ

ក្នុងសម័យប្រជុំវិទ្យាសាស្ត្រ ដែលបានប្រព្រឹត្តទៅនៅឯរាជវាំងរបស់អាល់-ម៉ាក់មូន ពួកសត្រូវរបស់អាស់លុល-បៃត៍ عليهم السلام សង្ឃឹមលើ យ៉ាស់យ៉ាប៊ិន អាក់ស្ថាំ (يحيى بن أكثم) ដើម្បីបំបាក់មុខអ៊ីម៉ាំអាល់-យ៉ាវ៉ាដ់ ។ បុរសកំណាចរូបនេះគុំកួនអាស់លុល-បៃត៍ عليهم السلام ល្បីថាជាបុគ្គលដែលពុំមានការអត់ឱនឡើយនៅក្នុងការពិភាក្សាក្នុងវិស័យវិទ្យាសាស្ត្រ និងនៅក្នុងការជជែករកហេតុផល ។ ពេលបានឃើញអ៊ីម៉ាំអាល់-យ៉ាវ៉ាដ់ឆ្លើយបានយ៉ាងងាយស្រួលគ្រប់សំណួរ ដែលគេបានសួរព្រះអង្គនោះ គាត់បាននិយាយដាក់ព្រះអង្គថា៖ «អាប៊ូ យ៉ាក់ហ្វារអើយ សូមឲ្យអល់ឡោះហ៍ عزوجل កែតម្រង់អ្នក ។ តើអ្នកយល់យ៉ាងណាអំពីបុគ្គលទ្រង់អ៊ិះហ៍រ៉ម (إحرام) ដែលបានសម្លាប់សត្វ?» អ៊ីម៉ាំបានតបថា៖ «តើបុគ្គលនោះបានសម្លាប់សត្វនោះនៅខាងក្រៅបរិវេណពិសិដ្ឋឬខាងក្នុង? តើបុគ្គលនោះដឹងថាត្រូវហាមឬទេ? តើបុគ្គលនោះបានសម្លាប់ដោយចេតនាឬដោយអចេតនា? តើអ្នកប្រមាញ់ជាជនមានសេរីភាពឬជាទាសៈ? តើបុគ្គលនោះចាស់ឬក្មេង? តើជាលើកដំបូងឬបានប្រព្រឹត្តអំពើនេះពីមុនម្តងហើយ? តើសត្វនោះជាបសុបក្សី (មាន់ ទា ក្ងាន ...) ឬជាសត្វផ្សេង?



